# ឯកសារទស្សនទាន

# កិច្ចប្រជុំស្តីពី

# ការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន និងការយល់ដឹងអំពីក្របខណ្ឌច្បាប់

**ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ នៅភ្នំពេញ**

## ១. សេចក្តីផ្តើម

តាមរបាយការណ៍សិក្សាស្រាវជ្រាវដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្នុងឆ្នាំ២០១២ បង្ហាញថា មានអង្គការសហគមន៍មូលដ្ឋានប្រមាណជាង ២៥០០០ (ពីរម៉ឺនប្រាំពាន់) ហើយពួកគាត់ដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍខាងផ្នែកសេដ្ឋកិច្ច សង្គម និងលើសពីនេះ។ ទោះបីជាយ៉ាងណា ការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជានៅតែត្រូវការការលើកកម្ពស់ និងគាំទ្រពីភាគីពាក់ព័ន្ធដទៃទៀត រួមទាំងដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងរដ្ឋាភិបាល។ ដើម្បីជាការចូលរួមក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍ និងក្រុមការងារបច្ចេកទេសគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជាបានបង្កើតឡើង។ ក្នុងកិច្ចអន្តរាគមន៍នេះ អង្គការ គ.ស.ក ក៏បានរៀបចំកិច្ចប្រជុំភាពជាដៃគូ ការប្រជុំតាមតំបន់ និងវេទិកាសិក្សាមួយចំនួន ដើម្បីពិភាក្សាស្វែងរកដៃគូប្រកបដោយបរិយាបន្ន ក្នុងការគាំទ្រអង្គការសហគមន៍មូលដ្ឋាន សម្រាប់ការប្រតិបត្តិល្អ និងនិរន្តរភាព ធ្វើការផ្សព្វផ្សាយ និងសិក្សារៀនសូត្រលើសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន។

ម្យ៉ាងវិញទៀត សម្រាប់និន្នាការបច្ចុប្បន្ន ច្បាប់ស្តីពីសមាគម និងអង្គកាមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសារពើពន្ធ គឺជាក្របខណ្ឌច្បាប់ដែលអាចប៉ះពាល់ដល់ការប្រតិបត្តិការ និងបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និងជីវភាពរបស់ពួកគាត់។ កាតព្វកិច្ចដែលទើបមកដល់ថ្មីមួយទៀតដែលជាការប្រឈមរបស់អង្គការសង្គមស៊ីវិលដែលនោះ គឺការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងគម្រូរបាយការណ៍។

ក្នុងន័យនេះ ដើម្បីអោយអង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជា យល់ច្បាស់ពីការអភិវឌ្ឍគោលនយោបាយ ការគោរពច្បាប់ទាំងនោះ ដើម្បីឲ្យពួកគាត់អនុវត្តការងារតាមបរិយាកាសបច្ចុប្បន្ន និងកាត់បន្ថយហានិភ័យដែលអាចនឹងកើតឡើងជាយថាហេតុ និងដើម្បីឲ្យពួកគាត់ត្រៀមខ្លួនសម្រាប់កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី «ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ឬភាសា

អង់គ្លេសហៅថា Cooperation Committee for Cambodia (CCC) នឹងរៀបចំកិច្ចប្រជុំការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន និងការយល់ដឹងអំពីក្របខណ្ឌច្បាប់។

## ២. វេទិកានេះមានគោលដៅចំបងៗគឺ៖

១. ដើម្បីធ្វើការឆ្លុះបញ្ចាំង ថាតើអង្គការសហគមន៍មូលដ្ឋានធ្វើការប្រតិបត្តិតាមគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន និងអភិវឌ្ឍសហគមន៍របស់គាត់បានដល់កម្រិតណា

២. ដើម្បីស្វែងយល់ពីបញ្ហាប្រឈមរបស់អង្គការសហគមន៍មូលដ្ឋាន និងតម្រូវការគាំទ្រពីអង្គការ គ.ស.ក និងអង្គការសង្គមស៊ីវិលដទៃទៀត

៣. ដើម្បីឲ្យអង្គការសហគមន៍មូលដ្ឋានត្រៀមខ្លួនសម្រាប់កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី «ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល»

## ៣. កាលបរិច្ឆេទ និង ទីកន្លែងនៃវេទិកាសិក្សា

**កាលបរិច្ឆេទ៖** ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ម៉ោង ១៖៣០រសៀល ដល់ ១៧៖០០

**ទីកន្លែង៖** ទីកន្លែងនៅ ដាយកូនៀ សិនធ័រ(ផ្ទះលេខ ១៩-២០ ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ)

## ៤. របៀបវារៈ

| *ម៉ោង* | *ការពិភាក្សា* | *អ្នកសម្របសម្រួល* |
|---|---|---|
| ១៣៖០០ ដល់ ១៣៖៣០ | ចុះឈ្មោះអ្នកចូលរួម | **លោកស្រី ស្រេង សោភ័ណលក្ខិណា** ជំនួយការកម្មវិធីការអភិវឌ្ឍសមត្ថភាព |
| ១៣៖៣០ដល់ ១៣៖៤៥ | ការណែនាំអំពីគោលបំណងនៃកិច្ចប្រជុំ | **កញ្ញា កៅ ពៅលក្ខិណា** អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ១៣៖៤៥ ដល់ ១៤៖០០ | សន្ទរកថាស្វាគមន៍ និងបើកកម្មវិធី ដោយអង្គការ គ.ស.ក | **លោក សៀង សារឿន** នាយកប្រតិបត្តិអង្គការគ.ស.ក |
| ១៤៖០០ដល់ ១៥៖០០ | ការពិភាក្សាជាក្រុមតូចៗ ត្រួតពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងខ្លួនឯងថាតើអង្គការសហគមន៍មូលដ្ឋានបានអភិវឌ្ឍសហគមន៍របស់គាត់បានដល់កម្រិតណា និងតើពួកគាត់កំពុងប្រឈមនឹងបញ្ហាអ្វីទៀត | **កញ្ញា កៅ ពៅលក្ខិណា** អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

| | | |
|---|---|---|
| | ហើយពួកគាត់ត្រូវការជំនួយអ្វីពីអង្គការ គ.ស.ក និងអង្គការសង្គមស៊ីវិលដទៃទៀត | |
| ១៥៖០០ ដល់ ១៥៖៣០ | ការធ្វើបទបង្ហាញពីក្រុមតូចៗទៅកិច្ចប្រជុំទាំងមូល | ទាំងអស់គ្នា |
| ១៥៖៣០ ដល់ ១៥៖៤៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ១៥៖៤៥ ដល់ ១៦៖០០ | បទបង្ហាញសង្ខេប អំពីខ្លឹមសារ និងដំណើរការ នៃកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិពី «ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល» | **លោក យឿង សុធារ៉ា**<br>អ្នកឯកទេសផ្នែកច្បាប់ |
| ១៦៖០០ ដល់ ១៦៖៤៥ | ការពិភាក្សាជាក្រុមតូចៗអំពីសំណួរ និងចម្ងល់ផ្សេងៗ ទាក់ទងទៅនឹងកាតព្វកិច្ចរបស់អង្គការសហគមន៍មូលដ្ឋានក្នុងការអនុវត្តច្បាប់ទាំងបី៖ ច្បាប់ស្តីពីសមាគម និងអង្គកាមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម | ទាំងអស់គ្នា |
| ១៦៖៤៥ ដល់ ១៧៖០០ | សុន្ទរកថាបិទ | **លោក សឿង សារឿន**<br>នាយកប្រតិបត្តិអង្គការគ.ស.ក |

**<u>កំណត់ចំណាំ៖</u>** អ្នករៀបចំកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈនៃកម្មវិធីខាងលើ ករណីមានការប្រែប្រួលចាំបាច់។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត